**នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/០៧-០៩-២០០៩-អវតក/កសចស |
| **ដាក់ទៅ** | : | សហចៅក្រមស៊ើបអង្កេត |
| **ថ្ងៃដាក់** | : | ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 08-Apr-2016, 15:10
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់ អមដោយឧបសម្ព័ន្ធសម្ងាត់មួយ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស: សម្ងាត់/Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរនៅក្នុង អាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងតំបន់១ និងតំបន់៤**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញាអន្តរជាតិ**
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
**សហព្រះរាជអាជ្ញាជាតិ**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Michael BOHLANDER

**ភាគីដើមបណ្ដឹងរដ្ឋប្បវេណី**
**ទាំងអស់នៃសំណុំរឿង០០៤**

**សហមេធាវី អោ អាន**
មុំ លុដ្ឋ
Göran SLUITER
Richard ROGERS

**សហមេធាវី អ៊ីម ចែម**
ប៊ិត ស៊ាងលឹម
John R.W.D. JONES QC

# I. សេចក្តីផ្តើម

1. ដោយអនុលោមតាមវិធាន ៥៥(២) និង ៥៥(៣)[1] នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាអន្តរជាតិ ("សពអ") នៅពេលនេះ សូមធ្វើការឆ្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("សចសអ") ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥[2]។

2. នៅក្នុងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ សចសអ ជូនដំណឹងដល់សហព្រះរាជអាជ្ញាថាកិច្ចស៊ើបសួរដែលកំពុងបន្តក្នុងសំណុំរឿង០០៤ បានឲ្យដឹងថា៖

   ក. វត្តវាំងកេសី ដែលមានទីតាំងស្ថិតនៅឃុំវាំងកេសី ស្រុកសង្កែ និងតំបន់នៃស្រុកសង្កែដែលបច្ចុប្បន្នស្ថិតក្នុងឃុំកំពង់ព្រាង មានភស្តុតាងអំពីអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលបានកើតឡើងក្នុងឆ្នាំ១៩៧៧ និង១៩៧៨ គ្រប់គ្រងដោយតំបន់៤ ប៉ុន្តែមិនស្ថិតក្នុង "ភាគពាយ័ព្យកណ្តាលនៃស្រុកសង្កែបច្ចុប្បន្នឡើយ[3]" ដូចបានឲ្យដឹងក្នុងកថាខណ្ឌ៤ ដល់ទី៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយ បង្ខំ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ នោះទេ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម"[4]) និង

   ខ. អាពាហ៍ពិពាហ៍ដោយបង្ខំ អាចកើតឡើងនៅតាមបណ្តាស្រុកនៃភូមិភាគពាយ័ព្យបន្ថែមទៅលើស្រុកសង្កែ ដូចជាក្នុងស្រុកមោងឫស្សី ស្រុកគាស់ក្រឡ និងស្រុកសំឡូត[5]។

3. ហេតុដូច្នេះ សចសអ ស្នើសុំឲ្យបញ្ជាក់បំភ្លឺ៖

   ក. ថាតើ វត្តវាំងកេសី តំបន់នៃស្រុកសង្កែដែលបច្ចុប្បន្នស្ថិតក្នុងឃុំកំពង់ព្រាង ស្រុកមោងឫស្សី ស្រុកគាស់ក្រឡ និងស្រុកសំឡូត តើតំបន់ទាំងអស់នេះស្ថិតនៅក្នុង

---

[1] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩), វិសោធនកម្មនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធាន")។

[2] **D272** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ, ៥ វិច្ឆិកា ២០១៥។

[3] **D272** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ, ៥ វិច្ឆិកា ២០១៥, កថាខណ្ឌ ក.២។

[4] **D191** សេចក្តីសន្និដ្ឋានបន្ថែម, ២៤ មេសា ២០១៤។

[5] **D272** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ, ៥ វិច្ឆិកា ២០១៥, កថាខណ្ឌ ខ.១។

វិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ ដូចបានជម្រាបជូនខាងលើដែរ ឬទេ[6]។

ខ. អំពីទីតាំងពិតប្រាកដនៅក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ ដែលមានបំណងគ្របដណ្ដប់ "ភាគពាយ័ព្យពាក់កណ្ដាលនៃស្រុកសង្កែបច្ចុប្បន្ន"[7] ហើយ

គ. ឧក្រិដ្ឋកម្មណាខ្លះដែលប្រើឃ្លាថា "ឧក្រិដ្ឋកម្មផ្សេងៗទៀត" ក្នុងកថាខណ្ឌ៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមបានគ្របដណ្ដប់[8]។

## II. ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ

4. ដោយបានពិចារណាទៅលើភ័ស្តុតាង ដែលបានលើកយោងនៅក្នុងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ សពអ បានជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត ("សចស") ថា អនុលោមតាមកថាខណ្ឌ១ និង៤ ដល់៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម សចស បានទទួល និងអនុញ្ញាតឲ្យដឹកនាំកិច្ចស៊ើបសួរឲ្យបានពេញលេញទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលអាចបានប្រព្រឹត្តឡើងនៅក្រោមអំណាចរបស់ យឹម ទិត[9] នៅក្នុងឆ្នាំ១៩៧៨ នៅស្រុកសង្កែ ដែលរួមទាំង៖

ក. តំបន់នៃស្រុកសង្កែនៅពេលតំបន់នេះជាផ្នែកនៃតំបន់១នៃភូមិភាគពាយ័ព្យ នៅក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ និង "រួមបញ្ចូលទាំងផ្នែកខាងកើតដែលឥឡូវនេះស្ថិតនៅក្នុងស្រុកបាណន់"[10] ហើយ

ខ. ទីតាំងនានាដែលបច្ចុប្បន្នស្ថិតនៅក្នុងតំបន់ព្រំប្រទល់នៃស្រុងសង្កែ ដោយមិនគិតអំពីថាតើទីតាំងទាំងនេះជាផ្នែកនៃតំបន់១ឬតំបន់៤ ក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យនោះទេ។

5. សពអ បញ្ជាក់ថា កថាខណ្ឌ៦ នៃដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមគួរត្រូវយោងទៅភាគឦសានកណ្ដាល ជាជាងពាក់កណ្ដាលទៅភាគពាយ័ព្យ នៅពេលស្វែងរកការពិព័ណ៌នាអំពីទីតាំងតំបន់៤

---

6 **D272** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ, ៥ វិច្ឆិកា ២០១៥, កថាខណ្ឌ ក.៣ក និង ខ.២។

7 **D272** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ, ៥ វិច្ឆិកា ២០១៥, កថាខណ្ឌ ក.៣ខ យោងកថាខណ្ឌ៦ នៃសេចក្ដីសន្និដ្ឋានបន្ថែម។

8 **D272** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ, ៥ វិច្ឆិកា ២០១៥, កថាខណ្ឌ ក.៣គ។

9 ដូចបានបញ្ជាក់លម្អិតក្នុង **D191** សេចក្ដីសន្និដ្ឋានបន្ថែម, ២៤ មេសា ២០១៤, កថាខណ្ឌ៥-៦។

10 **D191** សេចក្ដីសន្និដ្ឋានបន្ថែម, ២៤ មេសា ២០១៤, កថាខណ្ឌ៥។

ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងស្រុកសង្កែបច្ចុប្បន្ន។ នៅពេលដាក់ដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនោះ ព្រំប្រទល់ជាក់លាក់រវាងតំបន់១ និង និងតំបន់៤ មិនទាន់មាននៅឡើយ ទោះបីជាគេជឿជាក់ថា តំបន់៤ រួមមានតំបន់នានានៅភូមិភាគឦសាននៃផ្លូវរថភ្លើង[11] ឬផ្លូវជាតិលេខ៥ យ៉ាងណាក៏នោះទេ[12] (គូសបញ្ជាក់ដោយពណ៌បៃតង និងពណ៌ទឹកក្រូចនៅក្នុងផែនទីទាំងពីរតាមលំដាប់ក្នុង**ឧបសម្ពន្ធ ក**)។

6. ជាទូទៅ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមមានគោលបំណងស្នើសុំឱ្យ សចស ស៊ើបអង្កេតអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងទីតាំងទាំងនោះ ថាតើវាជាផ្នែកមួយនៃតំបន់១ ឬ តំបន់៤ នៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងណា។ ហេតុដូច្នេះ វិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការរួមបញ្ចូលទាំងតំបន់នៃស្រុកសង្កែ ដែលគ្របដណ្តប់ទាំងឃុំកំពង់ព្រៀងបច្ចុប្បន្ន និងដូចដែលបង្ហាញក័ស្តុតាងនៅក្នុងកថាខណ្ឌ៤ នៃដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម៖

ក. វត្តវាំងកេសី[13] និងភូមិវាំងកេសី[14] ក្នុងឃុំវាំងកេសី

ខ. វត្តនៅជិតទំនប់ កងហាត ដែលឥឡូវស្ថិតនៅក្នុងស្រុកបាណន់[15]

---

[11] **D6.1.173** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ សារឿន, ១៩ មិថុនា ២០០៨, ENG 000274618 ដូចដែលបានយោងនៅក្នុង **D191** សេចក្តីសន្និដ្ឋានបន្ថែម, ២៤ មេសា ២០១៤, ជើងទំព័រ២២។

[12] **D118/102**, កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទាត់ ធឿន, ១០ កញ្ញា ២០១៣, A27 ដូចដែលបានយោងនៅក្នុង **D191** សេចក្តីសន្និដ្ឋានបន្ថែម, ២៤ មេសា ២០១៤, ជើងទំព័រ២២។

[13] **D191.1.6** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី ចិច សុផា, ១២ ឧសភា ២០១០ និង **D191.1.7** សេចក្តីសង្ខេបលើឯកសារបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចិច សុផា, ៤ សីហា ២០១០។ **D191.1.81** សេចក្តីសង្ខេបលើឯកសារបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី រាជ សារី, ៤ សីហា ២០១០។

[14] **D191.1.87** សេចក្តីសង្ខេបលើឯកសារបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី សោម វណ្ណា, ៤ សីហា ២០១០។ **D191.1.49** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី ឡុង ឈឿម, ៣០ មេសា ២០១០ និង **D191.1.50** សេចក្តីសង្ខេបលើឯកសារបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឡុង ឈឿម។ (ទោះបីជាឯកសារទាំងនេះទាក់ទងនឹង ឡុង ឈឿម បង្ហាញថាគាត់បានរៀបការនៅក្នុងឃុំវាំងកេសីក៏ដោយ ក៏គាត់បាននិយាយថារូបគាត់បានរៀបការនៅក្នុងឃុំកំពង់ព្រះគ្រង់ A5 នៃ **D219/207** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ឈឿម, ២៥ កុម្ភៈ ២០១៥)។

[15] **D65.1.5b** សេចក្តីសង្ខេបលើឯកសារបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុត នឿន, ៤ សីហា ២០១០ និង ជាបន្ទាប់មកបានបញ្ជាក់តាមរយៈរបាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ឯកសារលេខ**D219/647** ចុះថ្ងៃទី ១៨ មករា ឆ្នាំ២០១៦។

គ.   ភូមិកាច់រទេះ ក្នុងឃុំកំពង់ព្រៀង[16] និង

ឃ.   ឃុំកំពង់ព្រះរួមបញ្ចូលទាំងភូមិថ្មី[17]។

7. សពអ បញ្ជាក់បន្ថែមទៀតថា ការយោងទៅលើ "ឧក្រិដ្ឋកម្មផ្សេងៗទៀត" នៅក្នុងកថាខណ្ឌ៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម មិនមានគោលបំណងពង្រីកការស៊ើបអង្កេតឱ្យហួសពីវិសាលភាពដែលបានកំណត់ពីមុនដោយដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបីរបស់សហព្រះរាជអាជ្ញាឡើយ ប៉ុន្តែដើម្បីទទួលស្គាល់ថាការស៊ើបអង្កេតរួមបញ្ចូលមន្ទីរសន្តិសុខចំនួនពីរ - មន្ទីរសន្តិសុខវត្តសម្តេច និងវត្តពោធិ៍ល័ង្កា- ដែលទំនងជាស្ថិតនៅក្នុងផ្នែកភាគពាយ័ព្យនៃស្រុកសង្កែ និងដែលអាចជាផ្នែកមួយនៃតំបន់៤ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងថាតំបន់ទាំងអស់នោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ យឹម ទិត[18]។

8. ជាចុងក្រោយ សពអ យល់ឃើញថា មិនចាំបាច់ពង្រីកការស៊ើបអង្កេតដើម្បីរួមបញ្ចូលអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងស្រុកមោងឫស្សី និងស្រុកគាស់ក្រឡ ដូចដែលបានរៀបរាប់លម្អិតនៅក្នុងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យឡើយ[19]។ សពអ ស្វែងរកការស៊ើបអង្កេតមួយដែលតូចល្មម និងមានប្រសិទ្ធភាព និងជឿជាក់ថា "កិច្ចដំណើរការនីតិវិធីមួយប្រកបដោយយុត្តិធម៌ អត្ថន័យ និងឆាប់រហ័ស"[20] មិនចាំបាច់មានការស៊ើបអង្កេតរាល់រឿងរ៉ាវដែលបានចោទប្រកាន់ទាំងអស់ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលបានប្រព្រឹត្តឡើងនៅក្នុងតំបន់នានាស្ថិតក្រោមអំណាចរបស់ យឹម

---

16 **D191.1.18** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម ប៊ុនឈឿន, ១២ ឧសភា ២០១០ និង **D191.1.20** សេចក្តីសង្ខេបលើឯកសារបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម ប៊ុនឈឿន, ៤ មេសា ២០១០។ **D191.1.29** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី ខឿន ចឹម, ៣០ មេសា ២០១០ និង **D191.1.31** សេចក្តីសង្ខេបលើឯកសារបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ខឿន ចឹម, ៤ សីហា ២០១០។ **D191.1.90** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី ស្រី សឿម, ៣០ មេសា ២០១០ និង **D191.1.92** សេចក្តីសង្ខេបលើឯកសារបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស្រី សឿម, ៤ សីហា ២០១០។

17 **D65.1.29b** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី សឿង ចាន់ថន, ៣០ មេសា ២០១០ និង **D191.1.86** សេចក្តីសង្ខេបលើឯកសារបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី សឿង ចាន់ថន, ៤ សីហា ២០១០។

18 សូមមើល ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣ របស់សហព្រះរាជអាជ្ញា, ២០ វិច្ឆិកា ២០០៨, កថាខណ្ឌ៦៨-៦៩។

19 **D272** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ, ៥ វិច្ឆិកា ២០១៥, កថាខណ្ឌ **៦**.១។

20 វិធាន៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង។

ទិត ដើម្បីបញ្ជាប់អំពីបទល្មើសព្រហ្មទណ្ឌនានាដែលមានរៀបរាប់នៅក្នុងកថាខណ្ឌ១៣ និង១៤ ខាងក្រោមនោះឡើយ។

9. យ៉ាងណាក៏ដោយ កិច្ចស៊ើបសួរត្រូវតែពង្រីកដោយរួមបញ្ចូលនូវអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងស្រុកសំឡូតផង ដោយសារមានហេតុផលនានាដូចបានចែងនៅក្នុងកថាខណ្ឌទាំងឡាយខាងក្រោមនេះ។ ដូច្នេះ ដោយអនុលោមតាមវិធាន៥៣ និង ៥៥(៣) នៃវិធានផ្ទៃក្នុង សពអ តាមរយៈឯកសារនេះ សូមធ្វើសេចក្តីសន្និដ្ឋានបន្ថែម ដូចតទៅ៖

## III. សេចក្តីសន្និដ្ឋានបន្ថែម

10. ការស៊ើបសួរដែលកំពុងបន្តធ្វើដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ធ្វើនិទស្សន៍បានថា គូស្រករប្រមាណជា៤០គូ ត្រូវបានបង្ខំឲ្យរៀបការនៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៨ នៅកន្លែងអតីតមន្ទីរស្រុកសំឡូត ក្នុងស្រុកសំឡូត ដែលជាតំបន់១ នៃភូមិភាគពាយ័ព្យ នៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[21]។ អាពាហ៍ពិពាហ៍ទាំងនេះត្រូវបាន តាម៉ុក និង យឹម ទិត ធ្វើជាគណៈអធិបតី[22]។

11. ក្នុងឆ្នាំ១៩៧៨ ស្រុកសំឡូតគឺស្ថិតនៅក្រោមអំណាចរបស់ យឹម ទិត ដែលជាលេខាតំបន់១[23] ក្នុងអំឡុងពេលមួយដែលគាត់ធ្វើជាគណៈភូមិភាគពាយ័ព្យផងដែរ[24]។ យឹម ទិត បានផ្តល់សេចក្តីណែនាំជាលាយលក្ខណ៍អក្សរ និងរបាយការណ៍នានា[25] បានដឹកនាំ និងបានថ្លែងនៅក្នុងការប្រជុំ នានា

---

[21] **D219/62**, កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប, ៣ វិច្ឆិកា ២០១៤, A31, A44-47, A50-51 និង A59។ **D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម, ១២ សីហា ២០១៤, A73 ហើយ **D219/298** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម, ០៧ ឧសភា ២០១៥, A6។

[22] **D219/62**, កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប, ៣ វិច្ឆិកា ២០១៤, A31, A44-47, A50-51 និង A59។ **D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម, ១២ សីហា ២០១៤, A73 ហើយនិង **D219/298** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម, ០៧ ឧសភា ២០១៥, A6។

[23] **D219/62**, កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប, ៣ វិច្ឆិកា ២០១៤, A44។ **D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម, ១២ សីហា ២០១៤, A7។

[24] សូមអាន **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣, ២០ វិច្ឆិកា ២០០៨, កថាខណ្ឌ ៣, ៥៨, ៦៧, ៩៤, និង ៩៥។ **D191** សេចក្តីសន្និដ្ឋានបន្ថែម, ២៤ មេសា ២០១៤, កថាខណ្ឌ៨។

[25] **D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម, ១២ សីហា ២០១៤, A44, A51 និង A82។

តាមតំបន់/ស្រុក[26] ហើយបានផ្តល់យោបល់ដល់ពួកអ្នកតំណាងស្រុកនានា នៅក្នុងតំបន់១ នៅពេលមានការប្រជុំផ្សេងៗ ឬនៅក្នុងអំឡុងពេលទស្សនកិច្ចរបស់គាត់ទៅកាន់ទីកន្លែងនានា អំពីបញ្ហាផ្សេងៗ រួមមាន "កម្មោចខ្មាំងដែលប្រឆាំងនឹងអង្គការ"[27] និងពីបញ្ហាដែលទាក់ទងនឹងសន្តិសុខ[28]។ ដូច្នេះ គាត់មានអំណាចក្នុងការអនុវត្តនូវគោលនយោបាយទាំងឡាយ ដូចជា អាពាហ៍ពិពាហ៍ដោយបង្ខំនៃប្រជាជនស៊ីវិលក្នុងស្រុកសំឡូតនេះជាដើម។

12. ជាលទ្ធផល សពអ សូមស្នើថា កិច្ចស៊ើបសួរមួយត្រូវតែបានបើកធ្វើ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងស្រុកសំឡូត ក្នុងអំឡុងឆ្នាំ១៩៧៨ នៅពេល យឹម ទិត មានអំណាចនៅទូទាំងតំបន់១ ដោយរួមទាំងព្រឹត្តិហេតុនៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៨ នោះផងដែរ។

13. សពអ មានមូលហេតុឲ្យជឿបានថា អង្គហេតុនានាដូចបានរៀបរាប់ខាងលើ រួមបង្កើតឲ្យមានឧក្រិដ្ឋកម្មនានា ដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការនេះ រួមមាន តែមិនកំហិតត្រឹមប៉ុណ្ណឹងទេ៖

ក. ការធ្វើទារុណកម្ម ជាការរំលោភ **ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦** (មាត្រា ៥០០) ដែលត្រូវផ្តន្ទាទោសតាមមាត្រា៣(ថ្មី), ២៩(ថ្មី) និង៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ (ច្បាប់ អ.វ.ត.ក)[29] និង

ខ. ការធ្វើឲ្យទៅជាទាសករ, ការដាក់ក្នុងមន្ទីរឃុំឃាំង, ការធ្វើទារុណកម្ម, ការរំលោភសេពសន្ថវៈ, ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗ

---

[26] **D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម, ១២ សីហា ២០១៤, A55 ហើយនិង **D219/298** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម, ០៧ ឧសភា ២០១៥, A14។

[27] **D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម, ១២ សីហា ២០១៤, A55-56 និង A92 និង **D219/298** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម, ០៧ ឧសភា ២០១៥, A16។

[28] **D219/298** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម, ០៧ ឧសភា ២០១៥, A22។

[29] ២៧ តុលា ២០០៤ (នស/រកម/១០០៤/០០៦)

ទៀត ដែលរួមបង្កើតបានជា **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ដែលត្រូវផ្តន្ទាទោសក្រោមមាត្រា៥, ២៩(ថ្មី) និង៣៩(ថ្មី) នៃច្បាប់ អ.វ.ត.ក។

14. សពអ មានមូលហេតុឲ្យជឿបានថា **យឹម ទិត ហៅ តាទិត, អោ អាន ហៅ តាអាន, អ៊ឹម ចែម** និងមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យដទៃទៀត រួមទាំង **នួន ជា** និង **ខៀវ សំផន** បានប្រព្រឹត្ត បានរៀបចំផែនការ បានញុះញង់ បានបញ្ជា ឬបានជួយ និងបានទំនុកបម្រុងអំពើព្រហ្មទណ្ឌជាក់លាក់ ដូចបានរៀបរាប់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម និងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ជាបទល្មើសមានចែងក្នុងច្បាប់ អ.វ.ត.ក។ អំពើទាំងនេះគឺជាផ្នែកមួយនៃផែនការឧក្រិដ្ឋកម្មរួម ឬសហកម្មឧក្រិដ្ឋកម្មរួម ដូចមានចែងក្នុងកថាខណ្ឌ២១ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១[30] និងកថាខណ្ឌ ១៦ ដល់ ១៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨[31]។

15. សេចក្តីសន្និដ្ឋាននេះ ត្រូវបានចុះហត្ថលេខាដោយសហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់គត់ អាស្រ័យហេតុនេះ សេចក្តីសន្និដ្ឋាននេះត្រូវធ្វើឡើងតាមវិធាន៧១(៣) នៃវិធានផ្ទៃក្នុង។ កំណត់ហេតុនៃការខ្វែងយោបល់គ្នានេះ ត្រូវបានដាក់នៅក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នាដែលបានរក្សាទុកដោយក្រឡាបញ្ជីសហព្រះរាជអាជ្ញា អនុលោមតាមវិធាន៧១(១) នៃវិធានផ្ទៃក្នុង៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ | **លោក** **Nicholas KOUMJIAN** សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | [signature and seal] |

[30] **D65** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម, ១៨ កក្កដា ២០១១។

[31] **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា, ២០ វិច្ឆិកា ២០០៨។